ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួនពីរ(០២)កន្លែង ជាតំបន់ប្រើប្រាស់ដោយចីរភាពសម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ រួមមាន៖

ក- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ១៦៦៨ហិកតា (មួយពាន់ប្រាំមួយរយហុកសិបប្រាំបីហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រុមហ៊ុន អេចធីធីអេច អាយឡែន អ៊ិនវេសមេន ឯ.ក (HTTH ISLAND INVESTMENT CO., LTD) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យទេសចរណ៍ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ១។



www.pheakdeylaw.com

ខ- ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ៤០៩ហិកតា (បួនរយប្រាំបួនហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រុមហ៊ុន CELESTIAL STARS LIMITED COMPANY ធ្វើការវិនិយោគអភិវឌ្ឍន៍គម្រោងសាងសង់ និងដំណើរការមជ្ឈមណ្ឌលកំសាន្ត រួមមានៈ សណ្ឋាគារ និងរីហ្សតអន្តរជាតិ ក្លឹបល្បែងផ្សងសំណាង(កាស៊ីណូ ឆ្នោតឡូតូ...) និងល្បែងភ្នាល់កីឡា។ល។ ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ២។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៩ រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ ១ ៖ អនុក្រឹត្យលេខ ១៤០ អនក្រ.បក
ថ្ងៃ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២០១៨

**ផែនទី ទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍វិស័យទេសចរណ៍ របស់ក្រុមហ៊ុន**
**អេចធីធីអេច អាយឡែន អ៊ិនវេសមេន ឯ.ក (HTTH ISLAND INVESTMENT CO., LTD)**
**នៅលើ«កោះថ្មី» ស្ថិតក្នុងឧទ្យានជាតិព្រះសីហនុ«រាម» ភូមិសាស្ត្រស្រុកព្រៃនប់**
**ខេត្តព្រះសីហនុ លើផ្ទៃដីទំហំ ១៦៦៨ ហិកតា**




ចំណុចនិយាមកា (HTTH)

| No | ID | X | Y |
|---|---|---|---|
| 1 | A | 362626 | 1163107 |
| 2 | B | 362182 | 1162888 |
| 3 | C | 362673 | 1162034 |
| 4 | D | 362814 | 1160769 |
| 5 | E | 365107 | 1157351 |
| 6 | F | 368340 | 1157351 |
| 7 | G | 368340 | 1159601 |
| 8 | H | 367369 | 1159601 |

**សញ្ញាសម្គាល់**

- ចំណុចនិយាមកាព្រំប្រទល់ដី
- ទីតាំងគម្រោងវិនិយោគ
- ព្រំប្រទល់ឧទ្យានជាតិព្រះសីហនុ «រាម»

N
W E
S
1:40,000
WGS_1984_UTM_Zone_48N
0 2 Km

ឧបសម្ព័ន្ធ ២ ៖ អនុក្រឹត្យលេខ ...១៥០ អនក្រ.បក...
ថ្ងៃ...[illegible]...ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ថ្ងៃទី...៤...ខែ...វិច្ឆិកា...ឆ្នាំ២០១៨

**ផែនទី ទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍សាងសង់ និងដំណើរការមជ្ឈមណ្ឌលកំសាន្ត រួមមានៈ សណ្ឋាគារ និងវីឡាអន្តរជាតិ ក្លឹបល្បែងផ្សងសំណាង (កាស៊ីណូ ឆ្នោតឡូតូ...) និងល្បែងភ្នាល់កីឡាៗលៗ របស់ក្រុមហ៊ុន CELESTIAL STARS LIMITED COMPANY នៅលើ«កោះថ្មី» ស្ថិតក្នុងឧទ្យានជាតិព្រះសីហនុ«រាម» ភូមិសាស្ត្រស្រុកព្រៃនប់ ខេត្តព្រះសីហនុ លើផ្ទៃដីទំហំ ៤០៩ ហិកតា**




ចំណុចព្រំប្រទល់ដី (CELESTIAL)

| No | ID | X | Y |
|---|---|---|---|
| 1 | A | 365107 | 1157351 |
| 2 | B | 368340 | 1157351 |
| 3 | C | 368349 | 1156918 |
| 4 | D | 368387 | 1156860 |
| 5 | E | 368234 | 1156076 |
| 6 | F | 367568 | 1155883 |
| 7 | G | 367021 | 1155888 |
| 8 | H | 366959 | 1155716 |
| 9 | I | 366424 | 1155390 |

សញ្ញាសម្គាល់

- ចំណុចនិយាមកាព្រំប្រទល់ដី
- ទីតាំងគម្រោង វិនិយោគ
- ព្រំប្រទល់ឧទ្យាន ជាតិព្រះសីហនុ «រាម»

N
W E
S

1:20,000

WGS_1984_UTM_Zone_48N

0 500 m